**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុមប្រឹក្សា
កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
អង្គភាពគ្រប់គ្រងគម្រោង
លេខ:០០៤/០៩ របក.អគគ

# របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ កុម្ភៈ ឆ្នាំ ២០០៩របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ កុម្ភៈ ឆ្នាំ ២០០៩ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោង ជាអង្គភាពប្រតិបត្តិ បានដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្ម ដែលបានកំណត់ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

## ១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌

### ក. ការងាររដ្ឋបាល

-ផ្ញើលិខិតស្នើសុំចាត់តាំងតំណាង ០១ ទទួលបន្ទុកការងារបណ្តឹងប្រជាពលរដ្ឋ និងអធិការ-កិច្ច របស់ក្រសួង ចូលរួមសិក្ខាសាលាស្តីពីការសិក្សាបញ្ចូលប្រព័ន្ធអំប៊ូស្មាន់នៅកម្ពុជា

-ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំក្រុមប្រតិបត្តិគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា

-ផ្ញើលិខិតស្នើសុំរៀបចំឯកសារ ស្តីពីការរៀបចំផែនការសកម្មភាពរបស់តុលាការទៅប្រធានសាលាដំបូង រាជធានីភ្នំពេញ

-ផ្ញើលិខិតអញ្ជើញ ចូលរួមប្រជុំក្រុមការងារបច្ចេកទេសចម្រុះ កំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០០៩

-ផ្ញើលិខិតស្នើសុំសម្ភាសន៍មន្ត្រីបីរូប ដែលបានចូលរួមសិក្ខាសាលាស្តីពីការរៀបចំស្ទង់មតិជាមូលដ្ឋាននៃ ការពង្រឹងអង្គភាពនីតិកម្មនៅតាមក្រសួង កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៩ នៅសណ្ឋាគារកាំបូឌីយ៉ាណា ទៅ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ផ្ញើលិខិតពន្យាពេលធ្វើសិក្ខាសាលាស្តីពីការសិក្សាបញ្ចូលប្រព័ន្ធអំប៊ូស្មាន់នៅកម្ពុជា ទៅថ្ងៃសុក្រ ទី៦ ខែមីនា ឆ្នាំ២០០៩ វេលាម៉ោង ៨ព្រឹក នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់

-ផ្ញើកំណត់បង្ហាញជូនឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាល ស្តីពីការកែសម្រួលទៅតាមការណែនាំរបស់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩។

-ទទួលលិខិតពីអគ្គលេខាធិការរងរាជរដ្ឋាភិបាល អញ្ជើញនាយកអង្គភាពគ្រប់គ្រងគម្រោង ដើម្បីចូលរួម ជាសមាជិកក្នុងពិធីបើកសន្និសីទអ្នកនិពន្ធអក្សរសិល្ប៍ កម្ពុជា-វៀតណាម-ឡាវ លើកទី២ ក្រោមអធិបតីភាព ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩។

-ទទួលលិខិតអញ្ជើញពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីចូលរួមកិច្ចប្រជុំស្តីពីវឌ្ឍនភាពប្រចាំ ឆ្នាំ២០០៨ នៃការអនុវត្តក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការ អភិវឌ្ឍន៍នៃប្រព័ន្ធអង្គការសហប្រជាជាតិ ឆ្នាំ ២០០៦-២០១០ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ វេលាម៉ោង ៨ៈ៣០នាទី នៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍ កម្ពុជា។

-ទទួលលិខិតបញ្ជូនមន្ត្រីចំនួន ០២រូប ពីរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចូលរួមសិក្ខា សាលាស្តីពីការសិក្សាបញ្ចូលប្រព័ន្ធអំប៊ូស្មាន់នៅកម្ពុជា កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩

- ទទួលលិខិតបញ្ជូនមន្ត្រីចំនួន ០២រូប ពីរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ចូលរួមសិក្ខាសាលា ស្តីពីការសិក្សាបញ្ចូលប្រព័ន្ធអំប៊ូស្មាន់នៅកម្ពុជា កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩។

## ខ. ការងារកំណែទម្រង់

-រៀបចំកិច្ចប្រជុំក្រុមប្រតិបត្តិគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ នៅសាលប្រជុំក្រសួងយុត្តិធម៌។

-រៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០០៩ វេលាម៉ោង ១៤ៈ៣០នាទី នៅសណ្ឋាគារសាន់វ៉េ។

-ចូលរួមកិច្ចប្រជុំស្តីពីការស្ទង់មតិក្នុងការពង្រឹងសមត្ថភាពនីតិកម្មនៅតាមក្រសួង ដោយជួបជាមួយនឹងក្រសួងពាក់ព័ន្ធមួយចំនួនដូចជា ៖ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួង ពាណិជ្ជកម្ម ក្រសួងអប់រំ យុវជន និងកីឡា។

-ចូលរួមប្រជុំជាមួយនឹង CCJAPIII និង EWMI ស្តីពីតុលាការគំរូ នៅថ្ងៃទី៧ ខែកុម្ភៈ និងថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩។

-ចូលរួមប្រជុំជាមួយក្រុមការងារតុលាការគំរូ ខេត្តកណ្តាលស្តីពីតុលាការគំរូ នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៩។

## គ. ផ្សេងៗ

-ចូលរួមប្រជុំអន្តរក្រសួង ដោយពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ ស្តីពីការបោះឆ្នោត និងការជួញដូរមូលបត្រមហាជន នៅថ្ងៃទី១៧-១៨-១៩ ខែកុម្ភៈ ឆ្នាំ២០០៩

-ចូលរួមប្រជុំអន្តរក្រសួងស្តីពីសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកែសម្រួលមាត្រា ១ និងមាត្រា ៦ នៃ ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងស្តីពីសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

-ចូលរួមសិក្ខាសាលាជាតិ ស្តីពីការផ្សព្វផ្សាយទិសដៅយុទ្ធសាស្រ្តនៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាល និង ការរៀបចំផែនការសកម្មភាព សម្រាប់ឆ្នាំ២០០៩-២០១៣ នៅថ្ងៃទី១៧-១៨ ខែកុម្ភៈ ឆ្នាំ២០០៩ សណ្ឋាគារ អាំងទែរកុងទីណង់តាល់។

-ចូលរួមកិច្ចប្រជុំអន្តរក្រសួង ពិភាក្សា និងប្រមូលផ្តុំមតិក្នុងការរៀបចំចងក្រង សេចក្តីព្រាងផែនការសកម្មភាពអភិបាលកិច្ចទី៣ (២០០៩-២០១៣) នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៩។

## ២-សន្និដ្ឋាន

ក្នុងខែ កុម្ភៈ ឆ្នាំ ២០០៩ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានរៀបចំកិច្ចប្រជុំក្រុមប្រតិបត្តិគម្រោង សិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា ដោយមានការចូលរួមពីស្ថាប័ន និងអង្គការមួយចំនួនពាក់ព័ន្ធ ហើយកិច្ចប្រជុំនេះបានទទួលនូវលទ្ធផលល្អ និងបាន រៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះ កំណែទម្រង់ច្បាប់ និងតុលាការ ដោយបង្ហាញអំពីវឌ្ឍនភាពនៃការអនុវត្តសូចនាករ និងការតាមដានរួមកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

## ៣-ទិសដៅអនុវត្តក្នុងខែបន្ត

-បន្តអនុវត្តគម្រោងតុលាការគំរូ

-បន្តអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ

-បន្តអនុវត្តគម្រោងប្រព័ន្ធទិន្នន័យស្តីពីការលើកកំពស់សិទ្ធិនៅតាមមូលដ្ឋាន

-បន្តអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការជាមួយ អទឈ

-គ្រោងរៀបចំសិក្ខាសាលាស្តីពីការសិក្សាបញ្ចូលប្រព័ន្ធអំប៊ូស្មាន់នៅកម្ពុជា។

-រៀបចំឯកសារសម្រាប់ធ្វើបទបង្ហាញ ស្តីពីភាពជឿនលឿននៃការអនុវត្តកម្មវិធីសកម្មភាពសម្រាប់ អនុវត្តយុទ្ធសាស្រ្តកំណែទម្រង់ច្បាប់ និងតុលាការ នៅពេលប្រជុំពិគ្រោះយោបល់ទ្វេភាគីថ្នាក់ជាន់ខ្ពស់ រវាងរដ្ឋាភិបាលកម្ពុជា និងប្រទេសដាណឺម៉ាក នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ និងរវាងកម្ពុជា និងចក្រភពអង់គ្លេស នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៩។

-ត្រៀមជួបលោកស្រី Maria Rasmussen មកពី DIHR ដើម្បីពិភាក្សាពីបញ្ហាកិច្ច សន្ទនារវាងរដ្ឋ និង សង្គមស៊ីវិល។

រាជធានី ភ្នំពេញ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៩

**អ្នកធ្វើរបាយការណ៍**

**ហ៊្វឹង សុកុល**

បានឃើញ និងឯកភាព

នាយកអង្គភាពគ្រប់គ្រងគម្រោង

**ស៊ុយ ម៉ុងលាង**